អាយុ៦-៨ឆ្នាំ

# ព្រះគម្ពីរសម្រាប់កុមារ មើលតាមរូបភាព

## សៀវភៅអនុវត្ត

សញ្ញាថ្មី២



KIDS WORSHIP
www.kidsworship.kr
Selah
Ministerio de Publicación Cristiano

# ព្រះគម្ពីរសម្រាប់កុមារមើលតាមរូបភាព

## សៀវភៅអនុវត្ត សញ្ញាថ្មី២

### អាយុ៦-៨ឆ្នាំ

កែសម្រួល kidsworship Selah

បកប្រែដោយ | KOMA Cambodia    រចនាក្រាហ្វិក | Jeewon Park, Julio Blas    ការកែសម្រួល | KOMA Cambodia

ហាមថតចម្លងទាំងស្រុង ឬផ្នែកណាមួយនៃសៀវភៅនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ

# លិបិក្រម


១. ឡាសារអ្នកសុំទាន ---------- 6

២. លោកសាខេ ---------- 10

៣. ព្រះយេស៊ូយាងចូលក្រុងយេរូសាឡិម ---------- 14

៤. ប្រាក់ពីរសេនរបស់ស្ត្រីមេម៉ាយ ---------- 17

5. ពិធីជប់លៀងចុងក្រោយបំផុត ---------- 20

៦. ឈើឆ្កាង ---------- 23

៧. ការមានព្រះជន្មរស់ឡើងវិញ ---------- 28

៨. ក្រុមជំនុំដើម ---------- 31

៩. លោកពេត្រុស (លោកពេត្រុសដែលបានប្រោសអ្នកខ្វិនឱ្យជា) ---------- 36

១០. ការស្លាប់របស់លោកស្ទេផាន ---------- 40

១១. សាវ័កប៉ុល ---------- 43


កុមារដែលថ្វាយបង្គំព្រះជាម្ចាស់ មានសុភមង្គល

# ចូរកត់ត្រាអំពីដំណើរនៃសកម្មភាព។

ចូរផាត់ពណ៌ បន្ទាប់ពីបញ្ចប់រឿងនីមួយៗ។

ស្កេន QR
ដើម្បីចូលទៅស្តាប់រឿង។



## រឿងទី១៖ ឡាសាអ្នកសុំទាន

**ខគម្ពីរ៖ លូកា១៦:២៥**

លោកអប្រាហាំមានប្រសាសន៍ថា "កូនអើយ! ចូរនឹកចាំថា កាលកូនមានជីវិតនៅឡើយ កូនស្គាល់តែសប្បាយ រីឯឡាសារវិញ គ្មានស្គាល់តែទុក្ខ។ ឥឡូវនេះ ឡាសារបានសុខក្សេមក្សាន្តហើយ តែកូនវិញ កូនត្រូវឈឺចុកចាប់

កាលដើមឡើយ មានអ្នកមានទ្រព្យស្ដុកស្ដម្ភម្នាក់។ គាត់រស់នៅក្នុងផ្ទះប្រណិត និងស្លៀកសំលៀកបំពាក់ថ្លៃៗ។
គាត់បរិភោគអាហារល្អបំផុតជារៀងរាល់ថ្ងៃ ហើយរស់នៅក្នុងភាពប្រណិត។ បុរសអ្នកមានហៅភ្ញៀវមកដើម្បីជប់លៀងនៅផ្ទះគាត់ជារៀងរាល់ថ្ងៃ។
គាត់មិនជឿព្រះទេ គាត់រស់នៅសម្រាប់តែខ្លួនឯង។ នៅមុខផ្ទះបុរសអ្នកមាន មានអ្នកសុំទានម្នាក់ឈ្មោះឡាសារ។
ឡាសារគាត់កើតដំបៅពេញខ្លួន ហើយតែងតែដេកនៅមាត់ទ្វាររបងផ្ទះអ្នកមាននោះ។ គាត់ស្លៀកសំលៀកបំពាក់កខ្វក់ ហើយគាត់បរិភោគកម្ទេចអាហារដែលជ្រុះពីតុអ្នកមានមក។ ប៉ុន្តែ ឡាសារជាមនុស្សដែលមានសេចក្ដីជំនឿរឹងមាំលើព្រះ។
ថ្ងៃមួយ ឡាសារក៏បានស្លាប់ទៅ។ ពួកទេវតារបស់ព្រះជាម្ចាស់បាននាំគាត់យកទៅនៅស្ថានបរមសុខ នាដើមទ្រូងលោកអប្រាហាំ ។
រីឯអ្នកមានក៏ស្លាប់ដែរ គេយកសពគាត់ទៅបញ្ចុះក្នុងផ្នូរ។ អ្នកមានធ្លាក់ទៅក្នុងស្ថាននរក ហើយរងទុក្ខទារុណកម្មយ៉ាងខ្លាំង។
ស្ថាននរកជាបឹងភ្លើងដែលឆេះមិនចេះរលត់។ បុរសអ្នកមានបានស្រែកដោយការឈឺចាប់។ គាត់ស្រេកទឹកខ្លាំងណាស់ ហើយបានស្វែងរកទឹក។
ក៏ប៉ុន្តែនៅទីនោះគ្មានទឹកទេ។ បុរសអ្នកមានបានងើយទៅលើ ក៏បានឃើញស្ថានបរមសុខ។
បុរសអ្នកមានភ្ញាក់ផ្អើលយ៉ាងខ្លាំង! គាត់ច្រណែននឹងឡាសារណាស់។ ដូច្នេះ គាត់បានស្រែកអង្វរលោកអប្រាហាំថា៖
«លោកឪពុកអើយ! សូមជួយខ្ញុំផង! រាងកាយខ្ញុំទាំងមូលកំពុងឆេះដោយអណ្ដាតភ្លើង។ វាពិតជាក្ដៅខ្លាំងណាស់! សូមលោកឪពុកប្រាប់ឡាសារឱ្យយកម្រាមដៃជ្រលក់ទឹកបន្តក់លើអណ្ដាតខ្ញុំបន្តិច ព្រោះនៅក្នុងភ្លើងនេះ ខ្ញុំឈឺចុកចាប់ណាស់»។
លោកអប្រាហាំតបថា៖ «កូនអើយ! ឡាសារមិនអាចទៅឯឯងបានឡើយ។ ចូរនឹកចាំថា កាលកូនមានជីវិតនៅឡើយ កូនស្គាល់តែសប្បាយ រីឯឡាសារវិញ គ្មានស្គាល់តែទុក្ខ។ ឥឡូវនេះ ឡាសារបានសុខក្សេមក្សាន្តហើយ តែកូនវិញ កូនត្រូវឈឺចុកចាប់។ម្យ៉ាងទៀត មានរណ្ដៅមួយយ៉ាងធំខណ្ឌយើងពីឯង ទោះបីយើងចង់ឆ្លងពីស្ថាននេះទៅរកឯងក៏ឆ្លងមិនបានឡើយ ទោះបីមានអ្នកណាចង់ឆ្លងពីឯងមករកយើង ក៏ឆ្លងមិនបានដែរ»។
បុរសអ្នកមាន មិនបានជួយឡាសារឡើយ ពេលដែលគាត់នៅរស់។ គឺគាត់មិនចេះស្រឡាញ់អ្នកជិតខាងឡើយ។
អ្នកណាដែលមិនចេះស្រឡាញ់អ្នកជិតខាងដូចបុរសអ្នកមាននេះ មិនអាចក្លាយជាប្រជារាស្ត្ររបស់ព្រះបានឡើយ។
ព្រះយេស៊ូបានបង្រៀនយើងឱ្យស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង។



**សកម្មភាពទី១** សូមកាត់រូបភាពខាងក្រោម រួចយកទៅបិទតាមលំដាប់លំដោយនៃខ្លឹមសារមេរៀនដែលបានរៀននៅថ្ងៃនេះ។

| | | |
|---|---|---|
| 1 | 2 | 3 |
| 4 | 5 | 6 |


















**សកម្មភាពទី២** សូមឆ្លើយនិងសំណួរខាងក្រោម។

a. តើអ្នកមានបានរស់នៅក្នុងជីវិតបែបណា?

---------------------------------------------------------------------------

b. តើអ្នកសុំទានមានឈ្មោះដូចម្ដេច?

---------------------------------------------------------------------------

c. ក្រោយពីស្លាប់ទៅ តើអ្នកមាននិងអ្នកសុំទាន ពួកគាត់ទៅណា? សូមសរសេរ។

---------------------------------------------------------------------------

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (លូកា១៦:២៥)

**កូនអើយ! ចូរនឹកចាំថា កាលកូនមានជីវិតនៅឡើយ កូនស្គាល់តែសប្បាយ រីឯឡាសារវិញ គាត់ស្គាល់តែទុក្ខ។**
**ឥឡូវនេះ ឡាសារបានសុខក្សេមក្សាន្តហើយ តែកូនវិញ កូនត្រូវឈឺចុកចាប់**